# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋម

សេចក្តីព្រាងអនុក្រឹត្យស្តីពី

ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ

## សេចក្តីផ្តើម

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ច ភាពក្រីក្ររបស់ប្រជាពលរដ្ឋត្រូវបានកាត់បន្ថយ និងការអភិវឌ្ឍលើគ្រប់វិស័យ។ ដើម្បីចូលរួមសម្រេចបាននូវចក្ខុវិស័យនេះ គឺត្រូវពឹងផ្អែកលើកត្តាធនធានមនុស្សជាចម្បង។ ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកិច្ចការមួយដែលទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងត្រូវប្រើប្រាស់រយៈពេលយូរអង្វែង។

ការលើកទឹកចិត្តសិស្សពូកែតាមរយៈការផ្តល់ជាអាហារូបករណ៍ ឬប្រាក់រង្វាន់ជ័យលាភីផ្សេងៗ គឺជាមធ្យោបាយសំខាន់មួយ ក្នុងការចូលរួមចំណែកជំរុញលើកទឹកចិត្តសិស្សានុសិស្ស ឱ្យខិតខំប្រឹងប្រែងរៀនសូត្រ ឈានឆ្ពោះទៅរកការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌។ កន្លងមក ការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែទូទាំងប្រទេស គឺធ្វើឡើងនៅកម្រិតមធ្យមសិក្សាចំណេះទូទៅសាធារណៈ និងឯកជន នៅថ្នាក់ទី៩ និងថ្នាក់ទី១២ លើមុខវិជ្ជាចំនួន ០៣ (បី) គឺ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា ដែលមានចំនួន ១០ ចំណាត់ថ្នាក់ គឺពីលេខ ១ ដល់លេខ ១០ ដែលប្រាក់រង្វាន់ជ័យលាភីលេខ១ ទទួលបានប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៨០០ ០០០ (ប្រាំបីរយពាន់) រៀល និងលេខ ១០ ទទួលបានប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៥៣០ ០០០ (ប្រាំរយសាបសិបពាន់) រៀល ដូចមានកំណត់នៅក្នុងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា។ ផ្អែកតាមខ្លឹមសារនៃអនុក្រឹត្យនេះ យើងសង្កេតឃើញថា ប្រាក់រង្វាន់ជ័យលាភីសិស្សពូកែមានចំនួនតិចតួច ដែលហាក់ពុំសមស្របទៅនឹងការខិតខំប្រឹងប្រែងរបស់សិស្សានុសិស្ស និងពុំឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ធនធានមនុស្សនៅកម្ពុជានាពេលបច្ចុប្បន្នឡើយ។

ដូចនេះ ជាការចាំបាច់ដែលក្រសួងគួរធ្វើការពិនិត្យ និងកែសម្រួលប្រាក់រង្វាន់ជ័យលាភីសិស្សពូកែទូទាំងប្រទេសនេះឡើងវិញ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍធនធានមនុស្ស និងលើកទឹកចិត្តអ្នកសិក្សាដែលមានសមត្ថភាព និងបញ្ញាខ្ពស់។

### ការកំណត់បញ្ហា

**១. ប្រាក់រង្វាន់លើកទឹកចិត្តមានចំនួនតិច**

បច្ចុប្បន្ន សិស្សានុសិស្សដែលកំពុងរៀននៅកម្រិតមធ្យមសិក្សាចំណេះទូទៅ សាធារណៈ និងឯកជន គឺមានចំនួនច្រើន ប្រហែលរាប់ម៉ឺននាក់នៅទូទាំងប្រទេស។ ការរៀបចំឱ្យមាននូវកម្មវិធីប្រឡងសិស្សពូកែ គឺធ្វើឡើងដើម្បីធ្វើការសម្រិតសម្រាំងជ្រើសរើសសិស្សដែលរៀនពូកែនៅតាមសាលានីមួយៗ ដែលត្រូវឆ្លងកាត់នូវការប្រឡងប្រជែងទាំងនៅថ្នាក់រាជធានី ខេត្ត និងនៅថ្នាក់ជាតិ ក្នុងចំណោមបេក្ខជនរាប់ម៉ឺននាក់។ កន្លងមក យើងសង្កេតឃើញថា ការផ្ដល់ប្រាក់រង្វាន់សិស្សពូកែដែលទទួលបានជ័យលាភី គឺមានចំនួនតិចតួច ដែលហាក់ពុំឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់សិស្សានុសិស្សដែលខិតខំប្រឹងប្រែងរៀនសូត្រឡើយ។ ដូច្នេះ ដើម្បីចូលរួមលើកទឹកចិត្តដល់ការខិតខំប្រឹងប្រែង និងការព្យាយាមរបស់សិស្សានុសិស្សក្នុងការរៀនសូត្រ ក្រសួងគួរបង្កើននូវការយកចិត្តទុកដាក់ដល់សិស្សពូកែទាំងនោះ ពិសេសគួរដំឡើងប្រាក់រង្វាន់លើកទឹកចិត្តដល់អ្នកសិក្សាបន្ថែមទៀត ។

**២. ប្រកួតប្រជែងលើឆាកអន្តរជាតិ**

ធនធានមនុស្សជាកត្តាសំខាន់ និងជាបរិបទសកល មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស។ ដោយព្រះរាជាណាចក្រកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព ទេពកោសល្យ និងសក្ដានុពលសម្រាប់ធានាការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិប្រកបដោយចិរភាព ទាមទារឱ្យមានការប្រកួតប្រជែងឱ្យស្របទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងក្នុងតំបន់ និងពិភពលោក។ ដើម្បីទទួលបានឧត្តមភាព និងជោគជ័យលើឆាកអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡា ដើរតួរយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពអប់រំ ទាំងទ្រឹស្ដី និងការអនុវត្ត (ការពិសោធន៍) ពិសេសការលើកតម្លៃដល់សិស្សពូកែ ដើម្បីជាមោទនភាពរបស់សិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល សាលារៀន សង្គមជាតិ និងពិភពលោក តាមរយៈការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្ត។ កន្លងមក បេក្ខជនរបស់កម្ពុជាយើង បានប្រឡងជាប់ក៏មែនពិត ប៉ុន្តែជាប់បានចំនួនតិច។ ដើម្បីបង្កើនលទ្ធផលឱ្យបានកាន់តែច្រើន និងកាន់តែល្អនោះ ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំឱ្យមានការលើកទឹកចិត្តពីក្នុងប្រទេសជាមុនសិន។

**៣. ការប្ដូរមុខវិជ្ជារូបវិទ្យា ទៅ ជាវិទ្យាសាស្ត្រ**

រូបវិទ្យាជាមុខវិជ្ជាមួយក្នុងបណ្ដុំមុខវិជ្ជាវិទ្យាសាស្ត្រ ដែលមានមុខវិជ្ជាបីសំខាន់គឺ រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ហើយរាល់ការប្រឡងសិស្សពូកែថ្នាក់តំបន់ និងពិភពលោក គឺគេផ្ដោតលើមុខវិជ្ជាវិទ្យាសាស្ត្រ ដែលក្ដោបមុខវិជ្ជាទាំងបីខាងលើ។ ដូច្នេះ ដើម្បីជាមូលដ្ឋានគ្រឹះអភិវឌ្ឍសមត្ថភាពរបស់សិស្សានុសិស្សឱ្យបានទូលំទូលាយ និងស្របតាមលក្ខខណ្ឌប្រឡងនានាខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានកែ

សម្រួលមុខវិជ្ជាពី «រូបវិទ្យា» ទៅ «វិទ្យាសាស្ត្រ» ដើម្បីឆ្លើយតបទៅនឹងបរិបទនៃការប្រកួតប្រជែងសិស្សពូកែលើឆាកអន្តរជាតិ។

## គោលបំណង

ការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះឡើង ក្នុងគោលបំណងផ្តល់តម្លៃ ផ្តល់កិត្តិយស និងលើកទឹកចិត្តឱ្យសិស្សខិតខំរៀនសូត្រដើម្បីប្រកួតប្រជែងនៅលើឆាកអន្តរជាតិ និងដើម្បីឱ្យក្លាយជាមូលធនមនុស្សសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល តាមរយៈការរៀបចំឱ្យមានថ្នាក់សិស្សពូកែ ការប្រឡងប្រជែងសមត្ថភាពសិស្សពូកែ និងកៀរគរការចូលរួមលើកទឹកចិត្តដល់សិស្សពូកែ។

## ជម្រើស

ដើម្បីដោះស្រាយបញ្ហាដូចមានលើកឡើងខាងលើ ក្រសួងអប់រំ យុវជន និងកីឡា គួរពិចារណាលើជម្រើសចំនួនពីរដូចខាងក្រោម ៖

**១.ជម្រើសទី១** ៖ រក្សាស្ថានភាពដើម ដោយបន្តអនុវត្តអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា ។

**២.ជម្រើសទី២** ៖ សេចក្តីព្រាងអនុក្រឹត្យថ្មី។

## ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពពួកកិច្ច និងផលចំណេញ

**១.ជម្រើសទី១** ៖ រក្សាស្ថានភាពដើម ដោយបន្តអនុវត្តអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា គឺក្រសួងត្រូវរក្សាបន្ទុកចំណាយចាស់ដដែល ដែលត្រូវចំណាយប្រហែល **៨១១ ៣៥៤ ៤០០** (ប្រាំបីរយដប់មួយលានបីរយហាសិបបួនពាន់ បួនរយ) រៀល ស្មើនឹង **២០២ ៨៣៨** ដុល្លារ ក្នុងមួយឆ្នាំ ដើម្បីជ្រើសរើសសិស្សពូកែតាមឆ្នាំសិក្សានីមួយៗ ។ ប្រសិន បន្តអនុវត្តអនុក្រឹត្យនេះដដែល ផលចំណេញនឹងទទួលបានតិចតួច ដោយសិស្សពូកែនៅតែទទួលបានប្រាក់រង្វាន់ជ័យលាភីតិច។

**២.ជម្រើសទី២** ៖ សេចក្តីព្រាងអនុក្រឹត្យថ្មី គឺត្រូវចំណាយប្រហែល **៨៥៦ ៩០៤ ៤០០** ( ប្រាំបីរយហាសិបប្រាំមួយលាន ប្រាំបួនរយបួនពាន់ បួនរយ) រៀល ស្មើនឹង **២១៤ ២២៦** ដុល្លារក្នុងមួយឆ្នាំ ដែលកើនបន្ទុកចំណាយចំនួន **៤៥ ៥៥០ ០០០** (សែសិបប្រាំលាន ប្រាំរយហាសិបពាន់) រៀល ស្មើនឹង **១១ ៣៨៧** ដុល្លារ ធៀបនឹងជម្រើសទី១ ដើម្បីជ្រើសរើសសិស្សពូកែតាមឆ្នាំសិក្សានីមួយៗ ។ ប្រសិន រៀបចំអនុក្រឹត្យថ្មី ផលចំណេញនឹងទទួលបានច្រើន ព្រោះនឹងបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ ជាពិសេសចំពោះសិស្សពូកែ។ លើសពីនេះ សិស្សានុសិស្សនឹងខិតខំរៀនសូត្រ នោះធនធានមនុស្សនឹងសម្បូរណ៍បែប ដែលអាចឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចដោយយកមូលធនមនុស្សជាមូលដ្ឋាន ព្រមទាំងអាចកាត់បន្ថយនូវភាពអស់សង្ឃឹម ឬគំនិតអវិជ្ជមានរបស់សិស្សបានផងដែរ។

## កិច្ចពិគ្រោះយោបល់បឋម

កិច្ចពិគ្រោះយោបល់ត្រូវបានធ្វើឡើងតាមរយៈ៖

- ការប្រជុំក្នុងក្រសួង និងបានស្នើសុំគោលការណ៍ដំឡើងប្រាក់រង្វាន់ពីរាជរដ្ឋាភិបាលកម្ពុជា

## សន្និដ្ឋាន

ផ្អែកលើការវិភាគអំពីបន្ទុកចំណាយនៃជម្រើសទាំងពីរខាងលើនេះបានបង្ហាញថា ជម្រើសទី២ មានការកើនបន្ទុកចំណាយច្រើនជាងជម្រើសទី១ ចំនួន **៩៥ ៩៥០ ០០០** (សែសិបប្រាំលាន ប្រាំរយហាសិបពាន់) រៀល ប៉ុន្តែបន្ទុកចំណាយដែលកើននេះ គឺកើនតែលើការដំឡើងប្រាក់រង្វាន់ជ័យលាភីសិស្សពូកែតែប៉ុណ្ណោះ ពុំមែនកើនលើបន្ទុកចំណាយក្នុងដំណើរការរៀបចំ និងការផ្តល់ប្រាក់បេសកកម្មជូនគណៈកម្មការរៀបចំការប្រឡងឡើយ ។ បើប្រៀបធៀបរវាងជម្រើសទាំងពីរនេះ ឃើញថាជម្រើសទី១ មានការចំណាយតិចពិតមែន តែផលចំណេញដែលទទួលក្នុងការលើកទឹកចិត្តសិស្សឱ្យយកចិត្តទុកដាក់ក្នុងការខិតខំរៀនសូត្រក៏មានតិចតួចដែរ ។ រីឯជម្រើសទី២ ទោះបីជាត្រូវចំណាយច្រើន ប៉ុន្តែនឹងមានផលចំណេញច្រើន ព្រោះប្រាក់រង្វាន់លើកទឹកចិត្តកើនដល់បីដង ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកទឹកចិត្តដល់សិស្សពូកែ ហើយក៏ឆ្លើយតបផងដែរទៅនឹងការខិតខំប្រឹងប្រែងរបស់សិស្ស។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា នឹងកាន់តែមានភាពងាយស្រួលក្នុងការជ្រើសរើសសិស្សពូកែ សម្រាប់យកទៅធ្វើការប្រកួតប្រជែងលើឆាកអន្តរជាតិផងដែរ។

ដូច្នេះ ជម្រើសទី២៖ សេចក្តីព្រាងអនុក្រឹត្យថ្មី គួរត្រូវបានពិចារណាជ្រើសរើស។

លទ្ធផលនៃវាយតម្លៃបឋមនេះ អាចទទួលយកបានដោយមិនចាំបាច់ធ្វើការវាយតម្លៃបន្តទៀតទេ។

## ការអនុវត្ត និងការពិនិត្យតាមដាន

ប្រសិនជាសំណើរៀបចំអនុក្រឹត្យថ្មីនេះត្រូវបានជ្រើសរើស វិធានការដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អក្នុងអំឡុងពេលប្រតិបត្តិគឺ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ជាពិសេសគណៈកម្មការប្រឡងជ្រើសរើសសិស្សពូកែ ។

ក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តត្រូវពិនិត្យនិងវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែងនៃការអនុវត្ត និងលើកជាយោបល់ជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច។ អនុក្រឹត្យនេះនឹងធ្វើការកែសម្រួលឡើងវិញ ប្រសិនបើរាជរដ្ឋាភិបាលមានឆន្ទៈក្នុងការកែសម្រួល។